Khmer Story Lovers


# អន្លង់មរណៈ

ប្រលោមលោកប្រឌិតបែបសម័យបុរាណចិន

ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ




អ្នកប្រែសម្រួល: អ.គឹមសាន


តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ៤


## វគ្គទី ៤

### ពាក្យសម្បថ

ស៊ី ឈិន និង ភ.យា ស្តាប់ដំណើរនេះសម្ងំគាំងមុខៗ ប្តូរ ព្រោះពាក្យសរសេរថានេះ មិនខុសពីពាក្យដែរ ស្តី ឬ ... នេះផៀលឡើយ ។

ខ្ញុំគិតមិនឃើញបន្តទៀត:

– លោកម្ចាស់ជួយពិចារណាផងមើល ? ពួកខ្ញុំដើរកក្នុងបន្ទប់មួយនៃផ្ទះសំណាកផញ្ញាំធំថ្មី ហើយនិយាយតិចៗណាស់ ម្តេចនឹងនាំឮ ? ដល់គេនិយាយមកវិញក៏ស្តាប់បានច្បាស់ណាស់, ដូចយើងអង្គុយទល់មុខគ្នាដែរ ?. ខ្ញុំងឿងណាស់ ។

ស៊ីឈិននិងភរិយាភ្ញាក់ផ្អើលដែរ នឹកដូចគ្នាថា:

– ចង់ស្តាប់គេនិយាយក្នុងបន្ទប់ ត្រូវមានប្រហោងមួយនៅជញ្ជាំង ឬលបស្តាប់កៀនទ្វារកៀនបង្អួចជាការមិនអាចទេ ។ ប៉ុន្តែការដែលនេះនេះនិយាយពីក្រៅ ឮដូចនិយាយខាងក្នុងជាមួយគេដែរ ដូចជាពិបាកណាស់ ពិតជាអ្នកគុននិយមខ្លាំងពូកែមិនខាន ។ តែ នេះពួកនេះដូចរឿងចចាមអារ៉ាមតែប៉ុណ្ណោះ !

ទឹកដដែលពោលចេ..

-ពួកយើងព្រួសដីនេះស្រឡាំងកាំងគ្រប់គ្នា ។ បន្ទាប់មកទើបបងវ៉ុនតំហាកសួរ:

- អ្នកណាថ្មើមធំពាសមេឃ, ហ៊ានមកស្លាប់ពួកយើង ? សែនចង់រស់ហើយឬ?

ដល់បងវ៉ុនតំហាក ដូនេះនោះសែងមាត់ភ្លាម ។ រំលងបានមួយស្របក់ ស្រាប់តែឮសម្លេងដែលពោល :

-អាគុនអើយ ! ពួកនេះសុទ្ធជាពួកក្រុមក្ខំទឹកកកទេ ហើយគ្រូវាជាមនុស្សដែលតាស្អប់ពិតពេកផងណា ! មិនដឹងចង្រៃអីមានក្មេងតូចម្នាក់ធ្វើឲ្យកញ្ជាស់ ... ខាងក្រុមក្ខំទឹកកកវិនាសព្រាត់ព្រាសកូនប្រពន្ធអស់រលីង ? ឯងគិតមើលគួរចម្លែកទេ ? ហាស់ ៗ...

ពួកយើងស្តាប់ដល់នេះ ទំងក្រហមមុខគ្រប់គ្នាចង់ស្ទុះទៅរកម្ចាស់សំឡេង តែបងវិចិត្រប្រញាប់កាងដៃឃាត់ពួកយើងឲ្យនៅស្ងៀមសិន ចាំស្តាប់គេតទៅទៀត ។ ពេលនោះឮសំឡេងក្មេងស្រីម្នាក់ពោល :

- កូនក្មេងធ្វើខ្លួនពូកែម្ល៉េះគេបានប៉ុណ្ណឹង ខ្ញុំសប្បាយណាស់តែខ្ញុំស្តាយត្រង់កញ្ជាស់ នោះមិនស្លាប់ណាលោកតា ! កាលណាទំនេរ តាចាំខ្ញុំទៅលេងក្ខំទឹកកកផងណា ! ចាំមើលខ្ញុំនិយាយឲ្យងាមឡូកញ្ជាស់ ... ឈឺចិត្តក្អួតឈាមស្លាប់ចំពោះមុខតាសប្បាយស្រើសហ្នឹង

ខិនភាន់ជុនប៉ិនហ៊ានហៅឈ្មោះគ្រូតាមដែលស្តាប់ឮនេះ ប្រហែលជានោះដាក់ឈ្មោះគ្រូគេថាម៉ែចហើយបានជាគាត់ចេះរំលងពេល ។ ស៊ុយឈឹងពោលថា:

- ដូនណាទោះព្រហ្មទីនណាស់ហ៊ានប្រមាថលោកអ៊ំប៉ាយដល់ថ្នាក់ហ្នឹង តើគេអាងអី ? យើងត្រូវស៊ើបសួរគេឲ្យឃើញ ។

វុនកុង់យីពោលតៈ

មែនហើយ ពព្រហ្មទីនណាស់គោងបួរជើតង់ផង់វ៉ះវិបអស់ក្តៅ ។ តែលោកម្ចាស់អើយ ! ពេលដែលយើងចំនួនចាំហ្វីងស្រាប់តែឮសូរចុះ គឺទ្វារមួយបើកទ្វារបើកផ្លូវឲ្យមនុស្សពីរនាក់ចេញទៅក្រៅ ។ ពួកយើងដកកាវុនវៀងខ្លួនប្រុងស្ទុះដេញតាមបងខិនភាដៃឃាត់ទៀត ! យើងឮមេហោរស្រែកថា :

- អាគុនថ្ងៃនេះយើងសម្លាប់មនុស្សបានប៉ុន្មានហើយ ?

មីក្មេងស្រីឆ្លើយ :

- ចេះតែបានមួយគត់ណា !

មេហោរកញ្ចាស់តប

- បើអ៊ីចឹងយើងអាចសម្លាប់បានពីរនាក់ទៀតដែរ ។

ស៊ីឈីងស្តាប់ដល់នេះលាន់មាត់ៈ យី ! មួយថ្ងៃមិនហួសបី !

ទិនភាន់ផុងដែលនៅស្ងៀមយូរហើយឮស៊ីឈីងពោលទាំងភ្ញាក់ផ្អើលក៏សួរយ៉ាងរញ្ជាប់ៈ

- លោកម្ចាស់ស្គាល់អាកញ្ចាស់នោះឬ ?

ស៊ីឈីងគ្រវីក្បាលៈ

- ខ្ញុំមិនស្គាល់ទេ តែធ្លាប់ឮខ្មោចឪពុកខ្ញុំដំណាលថាក្នុងពិភពគុនយើងមានជនមួយប្រភេទគេដាក់ឈ្មោះថា« មួយថ្ងៃមិនហួសបី» ព្រោះពួកគេអាចសម្លាប់មនុស្សក្នុងមួយថ្ងៃបីនាក់គត់លើសពីហ្នឹងគេទន់ដៃទន់ជើងលើកកាំបិតមិនរួចទេ ។

ទិនភាន់យីស្រែកដែរ ៈ

- អាហោរតិរច្ឆាន ! សម្លាប់មនុស្សមួយថ្ងៃបីនាក់ៗ ចែបរះមិនដាច់ពូជគេហើយ ឬ ? យ៉ន់យួនចែបហ្នឹងទុកឲ្យរស់យូរម្លេះ ?

ស៊ីឈីងពិចារណាទាំងស្រងូតស្រងាត់ថា ៈ

- ជនម្នាក់ត្រកូលទឹង ជាអ្នកក្លាហាននៅកណ្ដាលនគរខ្វល់ចិត្តសម្លាប់មនុស្សទាំងតណាៗ តែមិនដែលឮថា សម្លាប់ជនស្លូតត្រង់ត្រឹមត្រូវឡើយ ។

ទិនភាន់ផុងមិនឮស៊ីឈីងពោលអ្វីក៏សួរ ៈ

- តើមេហោរនោះឈ្មោះអីលោក ? រាន់នៅក្នុងក្រុមណាដែរ ?

- ឮគេថាជននោះត្រកូលទឹង តែមិនដឹងឈ្មោះពិតប្រាកដទេ ។ អ្នកគុនតិយមខ្លះហៅតាមគេថា "ទឹងមិនហួសបី" ព្រោះគេសម្លាប់មនុស្សមិនឲ្យហួសបីនាក់ៈ អាះណា

ទីភាន់ជ័នទឹងក្រោធស្រែក ៈ

- អាហោរអប្បលក្ខណ៍នេះចាំខ្ញុំសងគេមែន

ស៊ីឈីងពោលថា ៈ

- ជននោះល្បីល្បាញដែរ តែក្រែងលោកគិតបាយមានគំនុំអ្វីជាមួយគេណា បានជាគាត់មិន

និយាយរឿងពួកហ្នឹងប្រាប់អស់លោក ៗ រួចក្រោយមកយ៉ាងម៉េចទៀត ?

។ តមកតាប៉ិកញ្ចាស់នោះស្រែកថា មានតាម្នាក់ឈ្មោះស៊ិនវ៉ាន់នាន និងម្នាក់ទៀតឈ្មោះ ផូវ៉ាន់ឈុនដែរហ្នះ ? បើបានចេញមកណេះក្រោមឡើង ! អ្នកណាមិនមែនឈ្មោះអ៊ីចឹង កុំចេញមក ទោះចង់ស្លាប់ក៏យើងមិនខ្វល់សម្លាប់ដែរហ៊ុយ ព្រោះយើងមិនចង់ប្រឡាក់ដៃ

ពេលនោះពួកយើងទ្រាំមិនបានទៀត ក៏នាំគ្នាស្ទុះចេញទៅក្រៅអស់ រកមើលជុំវិញអត់ឃើញមនុស្សម្នាក់សោះ ។ ខ្ញុំលោតឡើងលើដំបូលផ្ទះ , ប្អូនខ្ញុំស្ទុះទៅដែកនេះបន្ទប់មួយនៅក្បែរនោះ គ្មានឃើញអ្វី ក្រៅពីទៀនមួយដើមនេះបំភ្លឺលើតុឡើយ ក្នុងពេលយើងកំពុងតែងឹកងល់ ស្រាប់តែលាន់សម្លេងកញ្ចាស់ដដែលពីក្នុងបន្ទប់យើងមកវិញថា ស៊ិនវ៉ាន់នានបានធ្វើអ្វីខ្លះនៅឡានចូវ ? ផូវ៉ាន់ឈុនបានធ្វើអ្វីខ្លះនៅឈើងចូវ ? កុំបាច់ឲ្យយើងរៀបរាប់នាំខ្មាសគេហ៊ុយ , ចេញមកជួបយើងក្រោមឡើង !

លោកបងស៊ិននិងបងផូទឹងប្រទេះឡាតហូតដាវស្ទុះចូលព្រមគ្នា ។ បងទិនស្រែកតាមក្រោយថា :

— ប្រយ័ត្នខ្លួន ! យើងចូលតាំងអស់គ្នាវិញ ។

រំពេចនោះភ្លើងបង្កៀងក្នុងបន្ទប់យើងរលត់ឈឹងយើងឥតព្រួសស្ងាត់សោះ ខ្ញុំស្រែកហៅបងស៊ិន បងផូ ទាំងភ័យស្ទន់គ្មានឮចម្លើយសោះ ក្នុងបន្ទប់គ្នាស្ងាត់ស្ងៀមក្នុងឥតគ្នាទៀត ពួកយើងព្រឺស្បែកគីងក់តែទំរត់ទៅល្បួចចូលទៅគួសភ្លើងបំភ្លឺបន្ទប់វិញ បងតាំងពីរលុតជង្គង់ត្រង់ក្តីតដាក់ដាវក្បែរខ្លួន ដូចរូបចម្លាក់ ។

បងទិននិងខ្ញុំស្ទុះទៅជួយលើកគាត់ស្រាប់តែគាត់រលំត្រេងផ្ងារចង្ក្រង់ ! បងស៊ិននិងបងផូវែកស្លានបោលយើងទៅដោយឥតខុកស្នាមរបួសត្រង់ណាសោះទេ ! ខ្លួនគាត់នៅក្តៅឧណ្ហៗ តែមិនដឹងអាព្រាយកញ្ចាស់នោះប្រើមន្តអាគមអ្វីសម្លាប់មនុស្សរហ័សលឿនបែបនេះ ? គួរចុកឈាមបំផុតត្រង់គ្មាននរណាឃើញស្រមោលវាតាំងពីម្តងសោះ ។

វ៉ុនវ៉ាន់ឃើញនិយាយចប់តែនៅស្ងៀមគ្រប់គ្នា ។ មួយសន្ទុះទើបស៊ុយឈឹងសួរ :

— មើលបងទិន ! រឿងហេតុអាក្លួនខ្ញុំហ្នឹងវាបក់ណើតតាំងពីកាលណាមក ?

— បាទនៅចុងឆ្នាំមុននេះឯង !

— បើអ៊ីចឹង ភូមិយើងខ្ញុំប្រហែលនេះខូចអស់ហើយ ព្រោះលោកបងប៉ាយចេញពីក្នុងកកកមក

ចំនួនបីខែស្រេច ។ ផ្លូវសូមអស់លោកជ្រាបណា៎ គឺគាត់ប្ដីប្រពន្ធខ្ញុំទៅរកការកូនចៅស្រីនោះឲ្យឃើញ ចាប់វាបានយកទៅក្នុងទឹកកកជូនលោកបងប៉ាយផ្ទាល់ដៃ ហើយធ្វើតពេលនោះសុំទោសលោកហ្វុនផង ។

ម្យ៉ាងទៀត ខ្ញុំចង់សុំបស្សូវដំណើរពីដនគ្រូសូលវីន "មួយថ្ងៃមិនហួសបី" ផង ។ បើខ្ញុំធ្វើមិនកើត ក៏គង់ខ្ញុំអាចជូនដំណើរខ្លះដល់លោកបងឲ្យគាត់ដោះស្រាយតាមនោះដែរ ។ ពេលនេះសុំលាសិន ។

ពោលចប់គាត់លើកដៃគោរពលាបង្វិលខ្លួនប្រញាប់ចេញទៅ ។ ទីភន់ដីនស្ទុះ:

– លោក... លោក មានប្រសាសន៍តែ២–៣ម៉ាត់អំពីចិនគិតបែកពីពួកយើងហើយឬ ?

– លោកបងមានការអីទៀត ?

– បើខ្ញុំរកកូនលោកមិនឃើញ ចង់សុំអញ្ជើញលោកប្រុសលោកស្រីទៅក្នុងទឹកកក ពិគ្រោះយោបល់លោកគ្រូខ្ញុំណា៎ !

– លោកពុកភ័យ, ខ្ញុំច្បាស់ជាវាក្នុងទឹកកកជាដាច់ខាត តែមុននឹងជួបលោកបងប៉ាយខ្ញុំត្រូវសុំបស្សូវឲ្យដឹងក្បាលកន្ទុយសិនដែរ ។

ទីភន់ដីនងាកមើលទិនកន់ដុន ហើយបែរមកនួនកន់ឃើទៀត ទើបពោលទាំងគំហឹងថា:

– បើលោកគ្រូជ្រាបថា ពួកយើងជួបលោកប្រុសលោកស្រី ហើយមិនអញ្ជើញលោកទៅក្នុងទឹកកក តើពួកយើង...

ស៊ីឈើនយល់ចិត្តពួកក្នុងទឹកកកភ្លាមតបវិញថា :

– លោកអ៊ំប៉ាយល្បីល្បាញខាងវល់ដែន ខ្ញុំតែងគោរពគាត់ដូចគ្រូឧបជ្ឈាយ ។ បើលោកនៅទីនេះដែរ គាត់ហៅខ្ញុំទៅណាក៏ខ្ញុំឥតហ៊ានប្រកែក, តែឥឡូវហ្ន៎ ! គិតយ៉ាងម៉េចអីចេះ? ណ្ហើយ ! រ៉ែវស្រាយដាវឯងមក !

គាត់ស្រាយដាវពីចង្កេះផ្ទាល់ អ្នកស្រីវ៉ាងយូក៏ស្រាយដាវហុចឲ្យប្ដីទៀត ។ ស៊ីឈើនហុចអាវុធទាំងគូរទៅទិនកន់ដុន ពោលបន្ថ :

– ខ្ញុំសុំបញ្ចាំអាវុធ ... ដីនបងទិនសិនចុះ ។

ទិនកន់ដុនដឹងច្បាស់ថាប្ដីប្រពន្ធនេះស្រឡាញ់អាវុធស្មើជីវិត ព្រោះដាវខ្មៅសរបស់ស៊ីឈើន និង

កិរិយាល្បីល្បាញពេញពិតពកុន ជាជាអាវុធពិសេសណាស់ , បើគាត់ជាប់ចិត្តប្រុងលំឡុមុន នឹង កិត្តិយសពិសេសម្រាប់ក្រុមក្នុងទឹកកកហើយ ។ វិនកាន់ដុងយល់ច្បាស់ម៉្យាងទៀតថា ស៊ុយឈីនមិនគេញ កិច្ចការរួចពិតជាទៅកាន់ក្នុងទឹកកកតាមជាវវិញជាពុំខាន ។

វិនកាន់ដុង គិតឃើញថែបនេះប្រុងពោលពាក្យគួរសមខ្វះដើម្បីទទួលអាវុធ ហើយស្រាប់តែ ទីកាន់ជីនស្រែកខ្លាំង :

– ហ៊ឹះ ! ជីវិតក្មួយស្រីយើងតាំងមូលណា ! លោកបងហ្នឹងជាក់ដៃខ្លាំង , អ្នកត្រូវតាមចេញ ពេលផ្ទុះ , បងស្រីម្នាក់វង្វេងសតិ.. បងជូនិងបងស៊ិនស្លាប់ពេលពួកយើងទៀត ដាវដែលគឺ នេះមិនអាចខូចក៏បានទេ ! បងវិនធ្លាប់ស្និទ្ធស្នាលនឹងលោកមែន ចំណែកយើង, យើងមិនដែល ស្គាល់លោកទេ ។ ថ្ងៃនេះទោះលោកចង់ ឬមិនចង់ ក៏ត្រូវទៅក្នុងទឹកកកសិនដែរ ។

ស៊ុយឈីនពោលទាំងញញឹម :

– អាក្អូនខ្ញុំមានកំហុសធំណាស់ ខ្ញុំគ្មានពាក្យអ្វីនឹងថ្លែងក្រៅពីសុំទោសអស់លោកទេ ។ បងទីជាសិស្សជំនាន់ក្រោយខាងក្នុងទឹកកកមានវិជ្ជាជ្រៅជ្រះណាស់, បងមិនស្គាល់ខ្ញុំមែនតែខ្ញុំធ្លាប់ឮ ឈ្មោះបងយូរណាស់ហើយ ។

ស៊ុយឈីនពោលបណ្តើរចេញដាវទាំងពីរបណ្តើរផ្តល់ទាំងវិនកាន់ដុងទទួលយក ។ កាន់ជីនគិតថា បើចង់ចាប់ប្តីប្រពន្ធគេត្រូវមានការប្រយុទ្ធបង្ហូរឈាមខាតជីវិតគ្នាទៀតផងក៏មិនដឹង, ហេតុនេះ ត្រូវទទួលដាវទុកសិនចុះ ។

ទីកាន់ជីនឃើញស៊ុយឈីនឈប់ហុចដាវស-ខ្មៅ ក៏ស្ទុះភ្លេតចាប់ទាំងអាវុធទាំងពីរជាប់ព្រមទាំងពោល :

– មិនអីទេខ្ញុំទទួលវត្ថុបញ្ចាំចិត្តនេះសិន ។

ពេលចប់ប្រុងថែរក្រោយដើរមកកន្លែងវិញ ស្រាប់តែមានកម្លាំងចំឡែកមួយ ស្រូបដាវទាំងពីរ ជាប់នឹងដៃស៊ុយឈីនរកដកមិនរួចសោះ ។ ទីកាន់ជីនភ្ញាក់ព្រើតស្រែកក៏សចំរើនកម្លាំងត្រូវគ្រាក់ដាវ អស់កំហឹង, ស៊ុយឈីនបន្ធូរដៃវិញ ឮប្រិប ! កាន់ជីន ស្រែកយ៉ូយទម្លាក់ដាវ ក្នុងដៃស៊ុយឈីនវិញប្រញាប់ ព្រោះដៃគាត់ប៉ោះ ភ្លឹងប្រឹងទាញលែងកើត ។

ទាំងអស់គ្នាភ្ញាក់ព្រើតដោយហេតុឃើញច្បាស់ថា ស៊ុយឈីនចេញដាវ នៅស្មៀមតែមានកំរើកម្រាមដៃ ផង ចំណែកទីកាន់ជីនត្រឡប់ជាចាប់បាមកញ្ជក់ខុសទំនងទាល់តែរងគ្រោះខ្លួនឯង ។ ទីកាន់

ដឹងឈឺណាស់ វិនឆ្លុះច្រមុះយារជើងទាត់ក្បាលពោះស៊ីឈីងក្រោម ។

វិនភន់ផុនស្រែកឃាត់យ៉ាងប្រញាប់ :

– កុំធ្វើផ្ដេសផ្ដាស !

ពេលផងស្ទុះទៅក្របួចខ្លួនភន់ផុនអូសថយក្រោយ មិនឲ្យជើងគាត់ទាក់ត្រូវពោះស៊ីឈីងព្រោះគាត់ដឹងច្បាស់ថា ម្ចាស់គូម៉នេះមានកម្លាំងស្ដុកស្ដម្ភណាស់ ទាត់ត្រូវតែមួយជើងទៀត មុខតែបាក់ ឬ គ្រេចជើងមួយមិនខាន ។

វិនភន់ផុនមានចំណេះទីងការពិសោធន៍ច្រើនផងវិភន់ផង បានជាគាត់ស្រួបវៀលបំប៉ោងសួតមួយដង្ហើមធំស៊ិនទើបលូកដៃសន្ធឹមៗទៅយកដាវ ។ ប៉ុន្តែប៉ះកេរុលលើដៃស៊ីឈីងក្ដាមគាត់ញ័រច្រើកទង្គួចត្រូវខ្សែភ្លើងឆក់ ដែលចាំងមានធាតុក្ដៅរត់ចូលដល់ខ្លួនទៀតផង ។ វិនភន់ផុនភ័យស្ងន់ស្ងៀមដឹងថាស៊ីឈីងចង់សាកល្បងកម្លាំងធាតុគាត់ហើយ ។

ការប្រយុទ្ធដែលអ្នកគុនមិយមទ្វាចញ្ចុះញើតជាងគេ គឺប្រយុទ្ធខាងកម្លាំងធាតុនោះឯង ព្រោះវាជាមធ្យោបាយតែមួយប្រាប់ប៉ុពុំញែកអនាគត ឬ ជីវិតតួបដិបក្ខ ។ កាលបើសាកល្បងខាងកម្លាំងធាតុហើយ គេនឹងមានម្នាក់របួសធ្ងន់ ឬ ស្លាប់ជាដាច់ខាត ប្រសិនបើគ្មានអ្នកវិជ្ជាដែលពូកែជានជួយបំបែកទាន់ ។ ព្រោះហេតុអស់នេះហើយបានជាវិនភន់ផុនភ័យព្រួយចំបើនកម្លាំងទប់ទល់វិញប្រញាប់ តែកម្លាំងគាត់ចេញទៅមិនរួចសោះ ចេះតែហ្រាំងមកវិញ ... ស៊ីឈីងត្រឡប់បាតដៃរហូតអាវុធចាំងតួរក់លើបាតដៃវិនភន់ផុនម្ដងរួចនិយាយ :

– យើងរាប់អានគ្នាយូរឆ្នាំមកហើយ មិនត្រូវស៊ីសងគ្នាទេ ។

វិនភន់ផុនបែកញើសពេញខ្លួនអស់ហើយ ព្រោះកម្លាំងធាតុគាត់ខ្សោយជាងស៊ីឈីងឆ្ងាយណាស់ បើលោកម្ចាស់គូមិនយោគយល់ ម៉្លេះគាត់អស់ជីវិតស្រេច ។ វិនភន់ផុនរំភើបចិត្តឥតឧបមាឈរកាន់ដាវរាំងពីរបៀសស្ងៀមឈឹងរកពាក្យនិយាយមិនបាន, ស៊ីឈីងសាកបបួលតវិយា :

– មក ! ត្រឡប់ទៅវិញ ។

វិនឃួចេញទឹកភ្នែករលីងរលោងសួរតិចៗ :

– ចុះកូនយើង ? . . .

ស៊ីឈីងគ្រវីក្បាល :

- កាត់ចិត្តទៅអូន . . . បណ្ដោយឲ្យគេសម្លាប់រាំជួបកូនទៀមប្រសើរជាង ។

នួនឃួស្រក់ទឹកភ្នែកព្រាកពោលទាំងអាក់អួលៈ

- បង . . . កូនអើយ . . .

ស៊ីណើងទាញដៃភរិយាតម្រង់សេះសជួយលើកដាក់លើខ្នងពាជី , សិស្សក្នុងទឹកកកទាំងឡាយឈរសម្លឹងមើលនារីជាឯក ដ៏ល្បីល្បាញដែលកំពុងកើតទុក្ខដូចស្ត្រីជាមាតាគ្រប់រូបគួរអាណិត ។

ហ្លួរាំងដឺឃើញ ស៊ីណើង នាំប្រពន្ធចាកចេញផុត ទើបត្រឡប់មកវិញឈរមើលនួនរាំងយ៉ឺ គដៃឲ្យទីរាំងជីន ដែលកំពុងដេរប្រទេចស៊ីណើងញាប់មាត់ ។ លុះស្ដាប់ដំណើររឿងសព្វគ្រប់ ហ្លួរាំងដឺ ជ្រួញចិញ្ចើមពោល :

- បងវិនក្ដុំ ! រឿងនេះថែបមិនស្រួលទេ ។

- មិនស្រួលយ៉ាងម៉េច ? លោកម្ចាស់ក្ងួម៉ាមានវិជ្ជាខ្ពង់ខ្ពស់ទាំងពីរនាក់ប្ដីប្រពន្ធណា ! ទោះយើងប្រួតគ្នាតែរាយមិនឈ្នះគាត់ដែរ , ត្រូវយកអាវុធទាំងពីរទុកបង្ហាញលោកគ្រូសិន គ្រាន់ស្រួលនិយាយការណ៍ ។ គាត់ពោលផងហូតដាវពីស្រោមផង, អាវុធមួយពណ៌សត្វថ្លាដូចកញ្ចក់, មួយទៀតពណ៌ខ្មៅព្រិតគ្រដាក់ស្រើប ជាអាវុធពិសេសមែន ។

វិនរាំងជុង មើលផ្ទៀងផ្ទង់ គ្រប់ជ្រុងរួចពោល :

- ដាវទាំងពីរនេះមិនមែនក្លែងក្លាយទេ ។

ហ្លួរាំងដឺពោលមួយៗ:

- ដាវនេះមិនក្លែងក្លាយមែន, តែពួកយើងមានគ្នាមួយគំនរ ឃាត់ម្ចាស់ក្ងួម៉ាមិនបានយ៉ាងនេះ ក្រែងការពារដាវគេមិនបានគង់វង់ណា !

វិនរាំងជុងភ្ញាក់ក្រញាង:

- ប្អូនហ្លួមានរឿងអីប្លែកឬ ?

- មិនប្លែកណាស់ណាទេ តែគួរពិចារណាដែរ ។ ថ្ងៃមួយខ្ញុំឮឥន្ទុយនិយាយលេងជាមួយបងប៉ាយអំពីគ្រឿងអាវុធវិសេសនៃពិភពគុន, កាលណោះអាចក្រៃស៊ីដុងយ៉ាស្ដាប់យើងដែរ រាំបានសរសើរដាវខ្មៅរបស់ម៉ែឥរាំជា វិសេសហើយមានតម្លៃស្លាប្រូមិនដែលឲ្យឃ្លាតពីប្រាណទេ ។ រាំជាន្ដាយរាំស្រឡាញ់រាំយ៉ាងណាក៏បញ្ជូនរាំទៅរៀនលើភ្នំទឹកកកទាំងខ្លួនទទេឥតឲ្យដាវមួយឡើយ ។

ឥឡូវស៊ីឈើងហ៊ានប្រគល់អាវុធទាំងពីរឡើប ក្រែងថ្ងៃក្រោយគេប្រើកលល្បិចលួចយកទៅវិញហើយ នៅក្នុងទឹកកកការយកជាវិគេវិញយើងមានស្អីសង ?

ទីភន់ជីនបញ្ចេញយោបល់:

– គ្នាយើងទាំង ៧ នាក់បើកភ្នែករំពៃមើលជាវមួយគូនេះកុំធ្វេសឲ្យសោះទៅណា ! ទាល់តែភន់ដុះស្លាប ឬ ចេះបំបាំងខ្លួន ទើបរបូតពីដៃយើងបាន ។

ទិនភន់ជុងសញ្ជឹងគិតបន្តិចទើបពោល :

– ប្អូនហ្លួគិតត្រូវម៉្យាងដែរ ព្រោះស៊ីឈើងមិនមែនមនុស្សធម្មតាទេ គាត់ប្រយ័ត្នមែនទែនទើបមិនចាញ់កលគាត់ ។

វុនភន់យីពោល :

– ត្រូវតែប្រុងប្រយ័ត្នអ៊ីចឹងហើយ ។ ពួកយើងប្រុសៗ៦នាក់ផ្លាស់វេនគ្នាយាមជាវពីរនេះឲ្យគង់, អូ,លោកបងទិនភ្លេ ! ប្តីប្រពន្ធស៊ីឈើងទៅទីក្រុងហើយ, យើងទៅដែរឬ ?

ទិនភន់ជុងនឹកថា បើមិនទៅដូចដាក់សាកណាស់ ប៉ុន្តែបើម្ចាស់ជាវខ្មៅ-សនៅទីណាយើងទៅទីនោះដែរ ក្រែងមានគ្រោះថ្នាក់ដីង ? ម្ល៉ោះហើយគាត់នៅស្ងៀមសញ្ជឹងគិត ។

ខណៈនោះឮសម្រែកឡូឡាមកពីឆ្ងាយ ហើយឃើញមនុស្សមួយក្រុមស្លៀកពាក់ជាឯកសណ្ឋាន ហែហមគ្រែស្នែងមួយធំតម្រង់មក ។ ទិនភន់ជុងយល់ថា ពិបាកនិយាយជាមួយពួកនេះ ក៏មិចភ្នែកឲ្យសញ្ញាគ្នាចេញដំណើរ ។ សមាជិកក្រុមភ្នំទឹកកកទាំង៧នាក់ប្រុងចេញទៅ ស្រាប់តែឮជនម្នាក់ស្រែកឃាត់:

– កុំរត់ទៅណា អាចោរឃាតករ !

ទិនភន់ជុងមិនខ្វល់ធ្វើព្រងើយតែបោយដៃបបួលគ្នាចេញដំណើរ,ជនដដែលស្រែកទៀត :

– ឯណា ឃាតករឈ្មោះ ប៉ាយដីតាយកញ្ចាស់នាយក្រុមភ្នំទឹកកក ? ប៉ាយដីតាយបាត់បង់កិត្តិយសហើយ, ឯងសម្លាប់មនុស្សប្លន់ទ្រព្យឬ? មិនចេះខ្មាសគេសោះអីចេះ ?

សិស្សទឹកកកទាំងអស់ខឹងក្រេវក្រោធថែមទាំងគិតភ័យយ៉ាងខ្លាំង ព្រោះប៉ាយដីតាយជាគ្រូធំលើគោលគ្នាមិនសមបើនសាមញ្ញ ជានាយសេនាបរិគេនេះហ៊ានប្រមាថជួរឆ្នះឡើយ ។ វុនភន់យី ហួតជាវឆ្វាកតំហកភ្លាម :

- អាឆ្កួតបំភាន់គេ ! គាត់អណ្ដាតឯងប្រគល់ឲ្យយើងសិនមកសឹមបរាជ័យទៀត !

ចិនវ៉ាន់ជុនឃាត់ :

- ឈប់សិនប្អូនអើយ, បំភាន់នេះស្គាល់រហស្សនាមណ.គ្រូច្បាស់ណាស់, ក្រែងមានអ្នកបញ្ជាទៅជាមួយណា :

ពេលចប់គាត់ស្ទុះភ្លែត.អះលើកដៃគោរព :

- អស់លោកខាងណាអញ្ជើញមកនេះ ?

ស្រាប់តែ ពូឈិប ! ការុធគូចំណូមួយរត់ចេញពីព្រៃស្ពានត្រូវដីពបរគាត់ទង់ជើងដួលប្រុសតែជាតិជាអ្នកក្លាហានមួយរូបខាងភ្នំទឹកកក, ។ ចិនវ៉ាន់ជុនមិនព្រមឲ្យគេដួលឆាយ ១ ទេ គាត់លើកជាវហោះទៅព្រៃស្ពានវិញភ្លាមតាមស្នៀត « កុកហើរជើងមេឃ» ។ ពំនូននៃព្រៃស្ពានវៃហកខ្ទាក, ចិនវ៉ាន់ជុនអះកើតទឹកថាបានស្គាល់មុខម្ចាស់ការុធសម្ងាត់មិនខាន ។ ប៉ុន្តែពេលនោះអ្នកកាន់ព្រៃស្ពាន ទាំង ៤ រត់រីងលោចំពាក់បួយវិលវាចាប់ ។ រុំជើងគាត់ជាប់ ។ អ្នកនៅក្នុងព្រៃស្ពានក្ដោកពាក់ឡើងខ្ទាតកាន់កាយចិនវ៉ាន់ជុនរុំដោយចំណងជាវខ្មៅភាញ្ញក្រឹមចូលក្នុងព្រៃស្ពានបាត់ ។

ហ្វូវ៉ាន់ជីស្រែក :

-លោកម្ចាស់ភូមិស៊ីឬ ?

ស្បូវផុងយាវជាវសកាប់ពោតធំ ស្រឈិប ! ការុធសម្ងាត់មួយដើមទៀត គប៉ុកកដៃនាងរបូតជាវជ្រុះដីបាត់ ។ ខណៈនោះសិស្សនាងម្នាក់ស្ទុះផ្លោតជាន់សង្កត់ជាវសេះ. តក្នុងពេលជាមួយគ្នានោះគេឃើញវត្ថុម្ជុលពណ៌ខ្មៅហើររឹងមកត្រូវក្បាលគេដែរ ។ សិស្សនោះក្រញាងណោតថយក្រោយវិញភ្លាមព្រមទាំងលូកដៃចាប់វត្ថុពណ៌ខ្មៅមកមើលទើបស្គាល់ជាម្ជុលអ្នកសេងព្រៃ ទំពាបាត់ភ័យ អ្នកនៅក្នុងព្រៃស្ពានហោលំពាក់វជាវសភាញ្ញដាក់ក្នុងនោះបាត់ស្រេច ។

ពួកភ្នំទឹកកកស្រែកនោះឡោវត់ដេញតាម, តែការុធសម្ងាត់ហើររ៉ាវៗ ចេញមកប្រហាចត្រូវសិស្សភ្នំទឹកកកគ្រប់ៗគ្នា គ្មាននរណាគេចផុតឡើយ ពិសេសការុធទាំងអស់ហោលត្រូវតែកន្លែងឥតគ្រោះថ្នាក់ពុំពិបាកឈឺចាប់ប៉ុន្មានប៉ុណ្ណោះ ។ អ្នកពល់គ្នារើសមកមើលទើបស្គាល់ច្បាស់ជាឡេវការស្មានដែលត្រូវប្រឡេះថ្នាំងាប់អំពោះនៅឡើយ ។ សិស្សភ្នំទឹកកកពល់រូបលប់កោតសរសើរដែនក្នុងព្រៃស្ពានថាមានវិជ្ជាខ្ពង់ខ្ពស់ណាស់មិនអាចយកឈ្នះបានឡើយ ។ ហ្វូវ៉ាន់ជីស្រែកខ្លាំងៗ:

–ត្រកូលស៊ីជាផនឃោរឃៅតាំងពុកតាំងកូនតែម្តង ! ទុកដាវឲ្យយើងហើយដេញតាមដណ្តើមវិញភ្លាម ។

ចិនកាន់ផ្លុំពោលតបៈ

– កុំឲ្យឡូពេក, រឿងនេះលេចឮខ្ចរខ្ចាយទៅឆ្ងាយមិនល្អចំពោះក្រុមយើងទេ , ចាំទៅដកបលោកគ្រូតាមហ្នឹងសិន ។

កាលដែលអ្នកសែងគ្រែគ្រាន់តែលឿននោះគេទៅដល់ផ្លូវបត់មួយរួចគេដើរតាមធម្មតាវិញ ។ រំពាត់ដដែលលូនចេញពីគ្រែស្នែងវាត់ខ្វាច់ៗ ទាល់តែអ្នកសែងគ្រែរបកសាច់ចេញឈាមហាមចំរត់ទៅមុខលឿនជាងមុន ។ លុះទៅឆ្ងាយផុតពីក្រុមប្រមុះពួកភ្នំកក់កើតផនោះ បន្តិចពាក់កណ្តាលគ្រែស្នែងថា :

– បានហើយ,ឈប់ត្រង់ហ្នឹងចុះ ។

សេនាតាំងដែលសែងគ្រែឮបញ្ជាដូចដកបន្លាពីទ្រូងម៉្យាងៗ ម្នាក់ស្នែងចុះដ៏យ៉ាងប្រញាប់ ជននោះបើកកំរាំងទ្វារកដើរចេញមកដឹកដៃកូនស្រូមម្នាក់ផង ។ គឺគ្មាននរណាក្រៅពីសែយានទី ម្ចាស់បញ្ជាដែកសំរិទ្ធិនិងស្រូមតូចកន្ទុកទេ ។ ចេញផុតភ្លាមគាត់គំហក :

–ឯងត្រឡប់ទៅវិញប្រាប់ទៅហ្វាយឯងថា រឿងនេះហេតុនៅថ្ងៃនេះមិនត្រូវនិយាយប្រាប់នរណាទេ, ប្រយ័ត្នអញដឹងអញនឹងវាយកណ្តាច់ក្បាលពួកឯងជ្រុះពីរ ណា !

សេនាតាំងអស់ទទួលយកពាក្យពោលព្រមគ្នា :

– ប្របាទ ! យើងខ្ញុំមិនហ៊ានហើបមាត់ទេ, សូមលោកអញ្ជើញដោយសេរីចុះ ។

សែយានទីគំហកទៀត :

– ស្អីចាំបាច់ឲ្យអញទៅដោយសេរីឯងឬ ? ឯងចង់ហៅគ្នាមកចាប់អញឬអី ?

សេនាម្នាក់ប្រញាប់កដៃ :

– ទានទេ ! ពួកខ្ញុំមិនហ៊ានឡើយ ។

– អើ ! ចុះពាក្យដែលអញផ្តាំឲ្យទៅប្រាប់ទៅហ្វាយឯងនោះគិតយ៉ាងម៉េចដែរ, ភ្លេចអស់ហើយហ៎ ?

– ខ្ញុំបាទចាំរត់ចាក់ហើយបាទ ! ខ្ញុំបាទទៅដល់ជំរាបលោកថាយើងខ្ញុំរើញកញ្ញាស់ម្នាក់ឈ្មោះ

ប៉ាយជីចាយសម្លាប់តាគមលក់នំនៅភូមិហ្វូវជានដោយកាំបិតមានភស្តុតាងជាក់ស្តែងណាស់ គឺខ្ញុំបានយកកាំបិតមួយប្រឡាក់ឈាមជូនគាត់មើល ។

សេនានេះពោលពាក្យបញ្ចេញបញ្ចូល ដើម្បីយកចិត្តស៊ែយានទី ព្រោះតាចាស់នេះអោយគាត់បាក់ស្បាតមិនហ៊ានជំទាស់នឹងបញ្ហាឡើយ - ស៊ែយានទីបង្ហាញចិត្តត្រឡប់ជាតឹងហកទៀត :

- ទេ ! កញ្ចាស់ប៉ាយមិនប្រើកាំបិតទេ គេប្រើដាវភោជាលៈប្បៀត !

- ប្របាទ ... ឃាតករកាន់ដាវមួយវែងចាក់ព្រួងតាគម ធ្លុះពីម្ខាងទៅម្ខាងមានអ្នកភូមិ ហ្វូវជានចាំងអស់ឃើញផ្ទាល់ភ្នែក ។

ស៊ែយានទីនឹកអស់សំណើច :

- បើប៉ាយជីចាយចង់សម្លាប់វូតាវអ៊ីគេមិនបាច់ប្រើអាវុធអីទេ ។

ស៊ែយានទីនឹកឃើញដូច្នេះមែន , តែគាត់លែងកំរើញសេនាល្អិតល្អោចក៏ដឹកដៃកូនស្ងួមដើរទៅមុខដោយរីករាយ ។

ក្បែតកាលជួបស៊ីឈីង និងវុនយូនៅភូមិហ្វូវជានដណ្តើមផ្ទាំងបញ្ហាដែកសំរេចបានហើយ , ស៊ែយានទីមិនអស់ចិត្តឡើយ ចេះតែបារម្ភខ្លាចក្ដីប្រពន្ធស៊ីឈីងលបលួចតាមបាចគាត់ ម៉្លោះហើយគាត់ធ្វើដំណើរទៅមុខមិនរួចទើបចុចជីពចរកូនស្ងួមដាក់ឡាញ់ដេកក្នុងគុម្ពោតព្រៃមួយ ។

ចំណែកខ្លួនគាត់ត្រឡប់មកស្ដាប់គេជជែកគ្នាវិញ ស៊ែយានទីមានវិជ្ជាខ្ពស់ណាស់ ទម្បីតែស៊ីឈីង និងកិរិយាដែលពូកែល្បីក៏មិនដឹងគាត់ពួនស្ដាប់ក្រោយគល់ឈើដែរ កុំថាត្រឹមពួកក្នុងភិកកក ។

ស៊ែយានទីលបមើលលបស្ដាប់ ដល់ស៊ីឈីងប្រគល់ដាវស និង ខ្មៅដល់ដៃ ខិនវ៉ាន់ផុង គាត់ប្ដេជ្ញាចិត្តថា ត្រូវដណ្តើមឲ្យបាន ។ គាប់ជួនពេលនោះមានមន្ត្រីរាជការជិះត្រៃស្នែងទៅអង្កេតរឿងឃាតកម្មនៅភូមិហ្វូវជាន ក៏គិតរកកំហែងមន្ត្រីរូបនោះដណ្តើមចាំងត្រែស្នែង ចាំងបំរើទ្យែសែងគាត់ និងកូនស្ងួមទៅដណ្តើមដាវ ។ ខិនវ៉ាន់ផុងនិងគូគាផតបានឃើញមុខគាត់នាំគ្នាស្មាន ស៊ីឈីងប្រព្រឹត្តអំពើចាបថោក ។

ពេលនេះស៊ែយានទីដឹកដៃស្ងួមម្ខាង ដៃម្ខាងកាន់ដាវចាំងតួដើរទៅរកខ្ទែងស្លាត់ នាមាត់ស៊ឹងក្រឡេកនាយកាយមិនឃើញស្រមោលមនុស្សទើបហួតដាវសង្ហាប់កស្ងួមតូចគំហកសួរ :

- ឯងខ្ញួលបញ្ហាពីអ្នកណាមក ? តែហ៊ានកុហក អញសម្លាប់ភ្លាម !

ពេលចាប់ពេលសំពាត់បែកកាប់ឈើតូចមួយដើមដាច់ត្រឹមធ្លាក់ក្នុងទឹកស្ទឹងញូរធ្លាក់ទៅ ៗ កូនស្ងួម ភ័យណាស់ធ្វើភ្នែកក្រឡឹបក្រឡាប់សួរ :

- ថាម៉េចខ្លួនបញ្ញា ?

សេរីយានទីលូកបញ្ចាសំរិទ្ធិមកបង្ហាញសួរម្ដងទៀត:

- របស់នេះអ្នកណាប្រគល់ឲ្យឯង ?

កូនក្មេងតបភ្លាម:

- ខ្ញុំ . . . ខ្ញុំស៊ីនំចេះវត្តហ្នឹងណា !

សេរីយានទីធុញទ្រាន់ណាស់ខ្ជិលសួរក៏យារៃផ្ដាំប្រុងខ្លះកំរៀនសូមកូនតាមចិត្តឡើ ៗ ប៉ុន្តែពេលបាត់ដៃទៀបប៉ះផ្ទាល់ដីកន្ទក់គាត់នឹកឃើញសង្ស័យថាមិនចំពោះផ្ទាល់អ្នកណា ដែលប្រគល់បញ្ចាសំរិទ្ធិឲ្យគាត់ឡើយ ៗ គាត់ក៏ប្រញាប់ខបកំហឹងផលដៃមកវិញទាំងយំ ហើយតំហាតទៀត:

- ឯងកុំនិយាយផ្ដាសាយ ! ស៊ីនំស្អី ? អញសួរថាអ្នកណាប្រគល់អ៊ីដែកនេះឲ្យឯង, ឮទេ ?

កូនស្ងួមចាប់ផ្ដើមភ័យ :

- ខ្ញុំស៊ីនំបង់ភ្ញាញ់ណា ! ខ្ញុំរើសពីដីមកស៊ីបានមួយចាំត,     ទាំងអ៊ីដែកហ្នឹងក៏បានចេញ

សេរីយានទីជាមនុស្សឆ្លាតវៃណាស់ដែរនឹកឃើញភ្លាមថារូបភាពអ៊ីលាក់បញ្ចាដែកសំរិទ្ធិនេះ ដែលនឹងមួយទៀតប្រាកែកថាមិនដែលមាននរណាល្អិតផលិតមុន ៗ បើបានបញ្ចាដែកសំរិទ្ធិហើយត្រូវពិចារណាការពារជួបជីវិតផ្ទាល់ម្ដេចហ៊ានយកទៅធ្វើនំលេង ?

គាត់មិនទាន់ផឹងថាស្ថានការណ៍ពេលនោះប្រែប្រួលញ៉ាបណាស់, រូបភាពអ៊ីយល់គាសខ្ញុំជួបមនុស្សលិចនឹកផល់នូវប្រមុះមិនដឹងលាក់ផ្ទាំងបញ្ចាក្រន់ណាក៏ធ្វើជាស្ងួលនំបង់ភ្ញាញ់ បង្ហាញមួយចំងៃទៀតត្រូវរែងទៅឲ្យសមាជិកក្រុមកាំបិតមាសដោយគាត់គាត់ថា នោះនៅដែកនោះគាស់កកាយក្នុងហ្វូងដានទាំងមូលក៏គ្មាននរណាចាប់ភ្ញាក់ផលនំបង់ភ្ញាញ់របស់គាត់ដែរ, ឃើញថារូបភាពអ៊ីមិនល្អទេ ៗ

ឥឡូវ សេរីយានទី សម្លឹងមុខកូនស្ងួមចំឡែកអស់ចិត្ត ទើបសួរថាថ្មី :

- ឯងឈ្មោះអី ?

- ខ្ញុំ... ខ្ញុំឈ្មោះអាក្ដែតគួជ !

សៃយ៉ានទី ភ្ញាក់ផ្អើលដោយការងឿងឆ្ងល់ :

- ស្អី ? ឈ្មោះកន្ត្រៃផែកពូជ? បាទ ៗ.... ខ្ញុំមិនដែលឮទេ !

- ម៉េចក៏អ៊ីចឹង ? ម៉ែខ្ញុំហៅកន្ត្រៃផែកពូជ យូរណាស់ ។ ខ្ញុំឮញស៊ីនអី ...

សៃយ៉ានទីជាមនុស្សកាចសាហាវចិត្តជូរអត់ធ្មត់តាមការៈទេសៈ មួយឆ្នាំមិនដែលសើច មួងទេ ។ ពេលនេះផ្ទុះប្រទះក្មេងកំភ្លត់ឈ្មោះរៃ្យកនិយាយពុំខុតពុំយកខុសឆោតស្រាំមិន បានសើចក្អាកក្អាយនឹកថា:

- ក្នុងលោកនេះមានម៉ែវង្វេះ ដាក់ឈ្មោះ កូនរៃ្យកវាមែន ដើម្បីឲ្យក្មេងនោះចាប់ចិត្តចាំថ្នាំឲ្យ ឃើញច្រើនគេសួរហើយហៅថាអាជ្រូក,អាឆ្កួញ,អាក្រឡុកអីផ្សេងៗ ។ល ។ តែមិនដែលឮឈ្មោះណាដាក់ ឈ្មោះ កន្ត្រៃផែកពូជទេ,ម៉ែអាតូចនេះចំឡែកមែន !

គាត់សើចពាល់តែកូនស្ទុះសើចតាមមួយចប់ទើបសួរ :

- ចុះឪពុកឯងឈ្មោះអី ?

- ឪពុក ? ខ្ញុំគ្មានឪពុកទេ ។

- ក្នុងផ្ទះឯងមាននរណាខ្លះ ?

- មានបីនាក់គឺ ម៉ែមួយខ្ញុំមួយនិងអាវ្លឹងមួយ ។

- អាវ្លឹងជាស្អី ?

-អាវ្លឹងជាឆ្កែខ្ញុំ ។ កាលម៉ែរត់ពីផ្ទះមក ខ្ញុំតាមរកគាត់,អាវ្លឹងក៏មកដែរ ។ ឥឡូវវាច្រើនឆ្នាំ ហើយព្រោះអាវ្លឹងដើរចុះឡើងរកចំណីស៊ីយូរៗណាស់ ។

សៃយ៉ានទីនឹកថា វាជាក្មេងល្ងីល្ងើទេតើ ប្រហែលវាកើតមានបញ្ហាស៊ីវិលមែនហើយ ពេលនេះយើងធ្វើយ៉ាងណាឲ្យវាអង្វរមួយម៉ាត់ឲ្យខ្លួនស្រេច ។

គិតឃើញដូច្នេះក៏ពោល :

- អាណាងភ្លា ! ឯងអង្វរយើង

គាត់ឈប់ត្រឹមណោះព្រោះនឹកបាត់គ្នាចសាតូចបន្ទាប់គាត់ទៅរកម្ដាយវាជួអាវ្លឹង តើគាត់ទៅរកទីណា ម្ដាយវាប្រហែលរត់តាមប្រុសឈ្នួល រីអាវ្លឹងប្រហែលគេចាប់ដាក់ទ្រុងឬវាយស្លាប់ទៅហើយ ។ ចើ ព្រើទៅសម្លាប់អ្នកការហាន១០នាក់ប្រហែលស្រួលជាង ។

ស្រីយានទីសញ្ជឹងគិតមួយស្របក់រួចពោល ៖

– នែតាតួច, យើងផ្តាំឯងមួយម៉ាត់ណា ៖ កាលណាជួបគេកុំនិយាយកេរយើងឲ្យសោះឮទេ ? បើនរណាប្រើក៏មិនត្រូវហាមាត់ដែរ ។ តែក្មេងអញកាត់ក្បាលឯងចោលហើយ

ស្រីយានទី យល់ច្បាស់ថារឿងនេះនឹងទៅជាយ៉ាងណាពិតពុំខានទើបគាត់ចាត់ការទុកជាមុនខ្លាចផែនទុច្ចរិតចោរកបញ្ឆោតស្តេចតូចនេះ ឲ្យធ្វើសណ្ឋានតាអ្វីមួយដែលមិនអាចបដិសេធបានព្រោះវាជាអ្នកច្រូគល់បញ្ហាដែលសំរិទ្ធិដល់គាត់ ។

ស្រីយានទីសួរក្មេងកន្ទក់ទៀត ៖

– ឯងស្តាប់បានទេ, យើងថាម៉េចខ្លះអម្បាញ់មិញ ?

– ថានរណាប្រើឲ្យនិយាយជាមួយលោក ខ្ញុំមិនត្រូវនិយាយទេ, បើហ៊ានហាមាត់លោកកាត់ក្បាលខ្ញុំហើយ ។

– អើគ្រាន់បើ ឯងមិនជាល្ងីល្ងើណាស់ណាទេ, មក !

ស្រីយានទីនាំកូនស្តេចដើរតាមផ្លូវថ្នល់ ដល់ផ្ទះតៀមមួយប្រមាណកំពស់របាយប៉ាវិញនិងទ្វារភានគស់ពីរ ។ គាត់ហៅលក្ខណ៍ស្តេចតូចចូលទៅតែហាមាត់ សុំមើលចាលចាកផុតពាក្យសម្បថហើយគាត់ពិសាផង ពោលពាក្យសរសើរនេនង. ដៃម្ខាងកាន់នំមួយ ហោលចុះហោលឡើងបង្ហាញកូនស្តេចឲ្យស្រក់ទឹកមាត់ ។

ស្រីយានទីដឹងណាស់ថាពាក្យសម្បថរបស់គាត់នឹងបញ្ហាដែលសំរិទ្ធមិនអាចយកឈ្នះមួយផ្លូវបានទេ ។ ប៉ុន្តែចំពោះក្មេងមួយរូបល្ងីល្ងើបែបនេះ គាត់យល់ថាជាការងាយស្រួលហើយងាយទៀត ។ ពេលនោះកូនស្តេចសម្លឹងមើលនំធំៗលេបទឹកមាត់ក្លែកៗកាលប្រាថ្នាចង់ហាមាត់សុំគាត់ដែរ ។ ស្រីយានទីបរិភោគនំមួយហើយមួយទៀតរួចលូកដៃយកនំពីក្នុងថានដាក់វិញ ។ កូនស្តេចទ្រាំមិនបានពោលទៅកាន់អ្នកលក់នំ ៖

– ឲ្យខ្ញុំពីរមក !

អ្នកលក់នំងើបមើលមុខស្រីយានទី, គាត់ងក់ក្បាលនឹកថា ៖

– ចាំមើលដល់គេហារលុយ ឯងសុំតញ្ញូ មិនសុំ ?

កូនស្តេចលូកយកនំបរិភោគយ៉ាងឆ្ងាញ់, អស់ពីរហើយយកពីរទៀតបរិភោគរលេបអស់. យ៉ា

-ខ្ញុំស៊ីឆ្អែតហើយ ។

សៃយានទីទទួលទានអស់នំពាំ សួរអ្នកលក់ថាប៉ុន្មានកាក់ ?

អ្នកលក់ឆ្លើយ

- នំមួយថ្លៃពីរកាក់ តាំងអស់ត្រូវជា១២កាក់លោក ។

សៃយានទីបានចិត្តក្រអឺតទឹកថាដល់ពេលហើយតាវ៉ ។ គាត់ឆ្លើយយ៉ាងច្រញាច់

- ទេ ! អ្នកណាស៊ីអ្នកហ្នឹងចេញលុយ ។ ខ្ញុំហូបអស់នំពីរ ត្រូវចេញលុយជូនកាក់ទេតើ !

ពោលហើយគាត់លូកហោប៉ៅរករកលុយកាយឥតប៉ះសោះ ព្រោះគាត់ផឹកស្រាកាលពីថ្ងៃត្រង់ អស់ពេលហើយ ។ សៃយានទីនេះកុញមិនដឹង

បកយកលើង នៅសល់តែថង់មាសឃើញថាពិបាកដូរណាស់ ។

គិតឃើញដូចម្ដេចផង កូនស្នំមខ្មះថង់ប្រាក់ប្រគល់ឲ្យអ្នកលក់ស្រេច

- អស់១២កាក់ខ្ញុំចេញលុយចុះ ។

សៃយានទីបើកភ្នែកក្រឡង់:

- អីយ៉ាអាល្អិត «ប៉ាវ» យើងផងរឺ !

កូនស្នំមសើចស្រេញ:

- បើលោកគ្មានលុយខ្ញុំប៉ាវលោកអ៊ីចឹងហើយ, មានពិបាកអី! កូនស្នំមៗរាប្រេកហោប៉ៅទុកភ្លាម

អ្នកលក់ងឿងឆ្ងល់ដៃទទួលថង់ប្រាក់មកទុកហើយថែមលុយកាយឲ្យកូនស្នំមៗ ។ សៃយានទីហួសចិត្តណាស់នឹកថា

រូបសម្ផស្សមុខសៃយានទីរង់ចាំទទួលបញ្ហា

-យើងជាមនុស្សតែលគោលម្នាក់ឯងមិនស្រវាំងនរណា កប់អាងហើយស៊ីផឹកមិនចេះដំណាក់នរណា

ទេ ។ ស្មានមិនដល់សោះថាថ្ងៃនេះហ៊ានរកគូប៉ាវ ។

គាត់សួរកូនស្នំមទៀតថា :

-ម៉េចឯងដឹងយើងអត់លុយ ?

-នៅផ្ទះខ្ញុំធ្លាប់ឃើញហើយ ។ កាលណាគេលូកដៃក្នុងហោប៉ៅមួយសន្ទុះមិនដកចេញវិញ

ហើយធ្វើមុខមិនស្រួលខ្ញុំត្រូវដឹងថាអត់លុយ ថាអ្នកនោះបាកគេស៊ី, លោកអត់ដឹងទេ !

(នៅមានត)

...លើកទី១ ចំនួន ២០០០ ច្បាប់